**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សុន្ទរកថា

## របស់ឧបនាយករដ្ឋមន្ត្រី គាត ឈន់

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មការមូលបត្រកម្ពុជា

## ថ្លែងក្នុងពិធី «សម្ពោធក្រុមហ៊ុនមូលបត្រ SONATRA Securities Plc»

**រាជធានីភ្នំពេញ, ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១១**

- **ឯកឧត្តមបណ្ឌិត អូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ**
- **ឯកឧត្តម លោកជំទាវ សមាជិក- សមាជិកានៃរាជរដ្ឋាភិបាល**
- **លោកឧកញ៉ា ស៊ីន សុខណា អគ្គនាយកក្រុមហ៊ុនមូលបត្រ SONATRA Securities Plc**
- **ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ជាភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ**

ថ្ងៃនេះ ខ្ញុំមានកិត្តិយស និង សេចក្តីសោមនស្សរីករាយ ដោយត្រូវបានអញ្ជើញជាអធិបតីនៅក្នុងពិធីបើកសម្ពោធដ៏អធិកអធមនៃការដាក់ឱ្យដំណើរការជាផ្លូវការក្រុមហ៊ុនមូលបត្រ **SONATRA Securities Plc** ដែលជាក្រុមហ៊ុនមូលបត្រមួយក្នុងចំណោមក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ **(Securities Broker)** ចំនួន ៤ ដែលទទួលបានអាជ្ញាប័ណ្ណពីគណៈកម្មការមូលបត្រកម្ពុជា ។

ការសម្ពោធដាក់ឱ្យដំណើរការក្រុមហ៊ុននាថ្ងៃនេះ ព្រមជាមួយនឹងការសម្ពោធដាក់ឱ្យដំណើរការជាបន្តបន្ទាប់នៃក្រុមហ៊ុនធានាទិញមូលបត្រ **(Underwriter)** នាពេលកន្លងមក ជាសក្ខីភាពបង្ហាញពីការត្រៀមខ្លួនរួចរាល់របស់អន្តរការីមូលបត្រ ដែលជាផ្នែកគន្លឹះមួយនៃហេដ្ឋារចនាសម្ព័ន្ធរបស់ប្រព័ន្ធទីផ្សារមូលបត្រ ។ ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ មានតួនាទីយ៉ាង

សំខាន់ក្នុងការជួញដូរមូលបត្រនៅទីផ្សារបន្ទាប់ តាមរយៈប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (CSX) ដែលការផ្ដល់សេវាជើងសាដល់សាធារណជននេះ គឺជាតួនាទីជាសារវ័ន្តមិនអាចខ្វះបាន នៅក្នុងដំណើរការទីផ្សារមូលបត្រ។ អត្ថិភាពនៃទីផ្សារនេះ នឹង បង្កើតនូវយន្តការកៀរគរទុនពីគ្រប់មជ្ឈដ្ឋានទាំងអស់ ដើម្បីផ្ដល់ហិរញ្ញប្បទានដល់វិស័យសេដ្ឋកិច្ចរបវន្ត ។ គួរបញ្ជាក់ថា ទុនដែលទទួលបានតាមរយៈទីផ្សារមូលបត្រនេះ ជាទុនដែលមានរយៈពេលវែង មានតម្លៃថោកសមរម្យ បើប្រៀបធៀបជាមួយប្រភពទុនផ្សេងទៀតដែលមាននៅក្នុងប្រព័ន្ធហិរញ្ញវត្ថុកម្ពុជាបច្ចុប្បន្ន ។ ទុនដែលកៀរគរតាមរយៈទីផ្សារមូលបត្រ និង ទុនដែលផ្ដល់ដោយប្រព័ន្ធធនាគារ ជាប្រភពទុនពីរដែលមានចរិកលក្ខណៈខុសពីគ្នា ទាំងបែបបទនៃការរុករកទុន ទាំងយន្តការនៃការប្រើប្រាស់ទុន ប៉ុន្តែទុនទាំងពីរនេះ ជាប្រភេទទុនដែលមានការបំពេញអោយគ្នាសម្រាប់តម្រូវការហិរញ្ញប្បទាននៃសេដ្ឋកិច្ចជាតិទាំងមូល ។ បន្ថែមលើនេះ អត្ថិភាពនៃទីផ្សារមូលបត្រ នឹងផ្ដល់នូវពិពិធភាវូបនីយកម្មសេវាកម្មរបស់ប្រព័ន្ធធនាគារ រួមទាំងការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុផងដែរ ។

## **ឯកឧត្ដម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី**

ដោយពិនិត្យឃើញសារៈសំខាន់ទាំងនេះរបស់ទីផ្សារមូលបត្រ រាជរដ្ឋាភិបាលបានអនុម័ត **«យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០៦-២០១៥»** ដែលជាយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរយៈពេលវែង ក្នុងនោះការបង្កើតទីផ្សារមូលបត្រ ជាអាទិភាពចម្បងមួយផងដែរ ។ បន្ថែមលើ **«យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០៦-២០១៥»** **«យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី២»** ដើម្បី **កំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព** របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក៏បានរំលេចយ៉ាងច្បាស់ផងដែរក្នុងការបង្កើត និង អភិវឌ្ឍទីផ្សារមូលបត្រនេះ ដោយផ្ដោតបន្ថែមលើការពង្រឹងការគ្រប់គ្រង និង អភិបាលកិច្ចសាជីវកម្មរបស់សហគ្រាសរដ្ឋ ដើម្បីឈានទៅការបោះផ្សាយលក់មូលបត្រជាសាធារណៈ ។

ជាមួយនឹងការខិតខំបំពេញភារកិច្ចយ៉ាងសកម្មរបស់គណៈកម្មការមូលបត្រកម្ពុជា និង ដោយមានការចូលរួមយ៉ាងសកម្មផងដែរពីវិស័យឯកជន និង ដៃគូអភិវឌ្ឍន៍នានា បទប្បញ្ញត្តិ

ជាមូលដ្ឋានសម្រាប់ដាក់ឱ្យដំណើរការទីផ្សារមូលបត្រត្រូវបានអនុម័តដាក់អោយអនុវត្ត។ ការដាក់ឱ្យដំណើរការទីផ្សារមូលបត្រនេះ ត្រូវបានសម្តេចតេជោនាយករដ្ឋមន្ត្រី ផ្តល់ការណែនាំដ៏ខ្ពង់ខ្ពស់ជាប្រចាំ ពិសេសពាក់ព័ន្ធនឹងការកំណត់គោលនយោបាយក្នុងវិស័យមូលបត្រ ដើម្បីឱ្យទីផ្សារមូលបត្រកម្ពុជាប្រព្រឹត្តទៅប្រកបដោយ **តម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព យុត្តិធម៌ និងការការពារដល់អ្នកវិនិយោគិនមូលបត្រសាធារណៈ ។**

**ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី**

ដើម្បីឱ្យទីផ្សារមូលបត្រដែលនឹងដាក់ឱ្យដំណើរការជាផ្លូវការនាពេលខាងមុខនេះ មានដំណើរការប្រកបដោយភាពជោគជ័យ រីកចម្រើន និង ផ្តល់ផ្លែផ្កាដល់សេដ្ឋកិច្ចជាតិ លុះត្រាតែតួអង្គទាំងអស់នៃប្រព័ន្ធទីផ្សារមូលបត្រមានគុណភាពល្អ មានជំនាញ និង វិជ្ជាជីវៈខ្ពស់ ព្រមទាំងមានឆន្ទៈ និង ទិសដៅអាជីវកម្មយូរអង្វែង ដូចយ៉ាងនៅថ្ងៃនេះ យើងទាំងអស់គ្នាចូលរួមសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការនូវក្រុមហ៊ុនមូលបត្រ **SONATRA Securities Plc** ដែលផ្តួចផ្តើមបង្កើតឡើងដោយលោកឧកញ៉ា **ស៊ិន សុខណា** ជាធុរជនខ្មែរឈានមុខគេម្នាក់រូប បានខិតខំស្វះស្វែងរកដៃគូដែលមានបទពិសោធន៍ខ្ពស់ក្នុងវិស័យមូលបត្រមកពីហុងកុង សិង្ហបុរី ចិន ជាដើម ដើម្បីបង្កើតជាក្រុមហ៊ុនមូលបត្រនេះឡើង ដែលក្រុមហ៊ុននេះមានសញ្ជាតិកម្ពុជា ។ នេះគឺជាមោទនភាពរបស់កម្ពុជា ដែលមានក្រុមហ៊ុនដែលមានសញ្ជាតិកម្ពុជា ចូលរួមក្នុងកិច្ចដំណើរការ និង អភិវឌ្ឍទីផ្សារមូលបត្រនៅកម្ពុជា តាំងពីដើមទី ។ ក្រៅពីការវិនិយោគក្នុងវិស័យមូលបត្រ លោកឧកញ៉ា ក៏បានវិនិយោគលើអនុវិស័យនៃវិស័យហិរញ្ញវត្ថុផ្សេងទៀត រួមទាំងវិស័យសេដ្ឋកិច្ចរូបវន្តជាច្រើនទៀត ។ លើសពីនេះ លោកឧកញ៉ា ក៏បានចូលរួមយ៉ាងសកម្មផងដែរក្នុងការបណ្តុះបណ្តាលដល់សាធារណជនតាមរយៈវិទ្យាស្ថានហិរញ្ញវត្ថុកម្ពុជា ដែលការបណ្តុះបណ្តាលនេះមានតួនាទីយ៉ាងសំខាន់ក្នុងការជម្រុញអោយទីផ្សារមូលបត្រកម្ពុជា ទទួលបានជោគជ័យ ។ ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះ តាងនាមឱ្យរាជរដ្ឋាភិបាលកម្ពុជា និង ក្នុងនាមខ្ញុំផ្ទាល់ ក៏ដូចអង្គពិធីទាំងមូល ខ្ញុំសូមសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការចូលរួមយ៉ាងសកម្មរបស់លោកឧកញ៉ា **ស៊ិន សុខណា** និង គណៈគ្រប់គ្រងរបស់ក្រុមហ៊ុនមូលបត្រ

SONATRA Securities Plc នៅក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុកម្ពុជា ក៏ដូចក្នុងវិស័យសេដ្ឋកិច្ចរួបវន្តរបស់កម្ពុជាទាំងមូលផងដែរ ។

ដោយពិនិត្យឃើញភាពជោគជ័យរបស់លោកឧកញ៉ា ក៏ដូចដៃគូវិនិយោគ ព្រមទាំងការប្តេជ្ញាខ្ពស់របស់គណៈគ្រប់គ្រងក្រុមហ៊ុន ខ្ញុំជឿជាក់ថា ក្រុមហ៊ុនមូលបត្រ SONATRA Securities Plc នឹងដើរតួនាទីយ៉ាងសំខាន់ និង ឈានមុខគេមួយនៅក្នុងទីផ្សារមូលបត្រកម្ពុជា។

**ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី**

ជាថ្មីម្តងទៀត តាងនាមឱ្យរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះលោកឧកញ៉ា **ស៊ន សុខណា** ក៏ដូចគណៈគ្រប់គ្រង និង បុគ្គលិកទាំងអស់របស់ក្រុមហ៊ុនមូលបត្រ SONATRA Securities Plc ដែលបានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលមានសម្តេចតេជោ **ហ៊ុន សែន** ជាប្រមុខដ៏ឆ្នើម ក្នុងកិច្ចអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ក៏ដូចសេដ្ឋកិច្ចកម្ពុជា ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរឱ្យក្រុមហ៊ុនមូលបត្រ SONATRA Securities Plc ប្រកបអាជីវកម្ម ដោយជោគជ័យ រុងរឿង និង រីកចម្រើនទៅថ្ងៃមុខ ព្រមទាំងទទួលបានទំនុកចិត្តពីសាធារណជន- ជាតិ និង អន្តរជាតិ និង សូមប្រសិទ្ធិពរជូនចំពោះ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ សិរីមង្គល វិបុលសុខ និង ជោគជ័យគ្រប់ភារកិច្ច- ធុរកិច្ច និង **សូមប្រកាសបើកសម្ពោធជាផ្លូវការក្រុមហ៊ុនមូលបត្រ SONATRA Securities Plc ចាប់ពីពេលនេះតទៅ** ។

**សូមអរគុណ !**